# ព្រះរាជក្រម

នស/រកម/១២១៩/០២៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង

# ឆ្នាំ ២០២០

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
## ថវិកាថ្នាក់ជាតិ

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ឱ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ ភិរភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឱ្យសម្រេចនូវឧបត្ថម្ភធនវិនិយោគនិងការខ្ចីតាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "**ក១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន៣០ ៣៩៥ ៨៥៥លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត.......................................................២៣ ៨៩៩ ៣២៤លានរៀល
- ចំណូលមូលធន....................................................៦ ៤៩៦ ៥៣១លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស.................................១៩៣ ៣៤១លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស...........................៦ ៣០៣ ១៩០លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..........................................................២៥០ ០០០លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ....................................................៦ ០៥៣ ១៩០លានរៀល។

**មាត្រា២ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង៣១ ០៩៥ ៨៥៥លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.......................................................១៨ ០៣៦ ៨៨៤លានរៀល
- ចំណាយមូលធន....................................................១៣ ០៥៨ ៩៧១លានរៀល

ក- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស
.............................................................................៥ ៨៩៩ ៨៥៩លានរៀល

- ដោយថវិកាថ្នាក់ជាតិ...............................៥ ៦៤៩ ៨៥៩លានរៀល
  - គម្រោងវិនិយោគផ្ទាល់...............៥ ០១៩ ៨៥៩លានរៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស ............................................... ៦៣០ ០០០លានរៀល

- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ ..........................................................២៥០ ០០០លានរៀល

ខ- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ..........................................................៦ ០៥៣ ១៩០លានរៀល

គ- ការទូទាត់ការខ្ចី........................................ ១ ១០៥ ៩២២លានរៀល។

**មាត្រា៣ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ស្មើនឹង១៨ ០៣៦ ៨៨៤លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "**ខ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៤ .-**

ចំនួនទឹកប្រាក់នៃឥណទានចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ត្រូវបានកំណត់ស្មើនឹង៣៧ ៤២៣ ៦២៨លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗតាមគម្រោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "**គ១**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៥ .-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា............................... ១៣ ០៥៨ ៩៧១លានរៀល
- ឥណទានទូទាត់.................................. ១៣ ០៥៨ ៩៧១លានរៀល។

ឥណទាននេះត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា.................................. ៥ ៨៩៩ ៨៥៩លានរៀល
- ឥណទានទូទាត់........................................ ៥ ៨៩៩ ៨៥៩លានរៀល

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា................................៦ ០៥៣ ១៩០លានរៀល
- ឥណទានទូទាត់.....................................៦ ០៥៣ ១៩០លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា................................១ ១០៥ ៩២២លានរៀល
- ឥណទានទូទាត់...................................១ ១០៥ ៩២២លានរៀល។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗដូចមានចែងក្នុងតារាង "**គ២**" និង"**ឃ**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា៦ .-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ ដែលត្រូវបានរៀបចំនៅក្នុងតារាង "**ក១**" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "**ខ១**" ស្តីពីចំណាយថវិកាថ្នាក់ជាតិមានបង្ហាញនៅក្នុងតារាង "**ង**" ភ្ជាប់មកជាមួយច្បាប់នេះ ដែលត្រូវបានកំណត់ដូចខាងក្រោម ៖

- ចំណូលក្នុងប្រទេសសរុប.....................................២៤ ០៩២ ៦៦៥លានរៀល
  - \+ ចំណូលចរន្ត............................................២៣ ៨៩៩ ៣២៤លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស................................១៩៣ ៣៤១លានរៀល
- ចំណាយថវិកាសរុប.........................................២៩ ៩៨៩ ៩៣៣លានរៀល
  - \+ ចំណាយចរន្ត...........................................១៨ ០៣៦ ៨៨៤លានរៀល
  - \+ ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី).......១១ ៩៥៣ ០៤៩លានរៀល
- អតិរេកនៃថវិកាចរន្ត.......................................(+)៥ ៨៦២ ៤៤០លានរៀល
- ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ...........................(-)៥ ៨៩៧ ២៦៨លានរៀល
- ហិរញ្ញប្បទាននៃឱនភាព..................................(+)៥ ៨៩៧ ២៦៨លានរៀល
  - \+ ហិរញ្ញប្បទានក្រៅប្រទេស.........................(+)៥ ១៩៧ ២៦៨លានរៀល
  - \+ ហិរញ្ញប្បទានក្នុងប្រទេស..............................(+)៧០០ ០០០លានរៀល
    - បញ្ញើរាជរដ្ឋាភិបាល.............................(+)៧០០ ០០០លានរៀល។

## ជំពូកទី២
## ការខ្ចីនិងការធានារបស់រដ្ឋ

**មាត្រា៧ .-**

សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ អនុម័តយល់ព្រមឱ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត១ ៤០០ ០០០ ០០០SDR(មួយប៊ីលានបួនរយលានអេសដេអ៊ែ)។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ។

នៅក្នុងលក្ខខណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់ តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការចុះហត្ថលេខាលើការខ្ចី ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ហើយត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តនៃការខ្ចីនិងការធានានេះ ជូនរដ្ឋសភានិងព្រឹទ្ធសភារៀងរាល់ ៦ខែម្ដង។

**មាត្រា៨ .-**

មិនអនុញ្ញាតឱ្យក្រសួង ឬស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋ មានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ។

## ជំពូកទី៣
## បទប្បញ្ញត្តិស្ដីពីពន្ធដារ

**មាត្រា៩ .-**

មាត្រា៩ ថ្មី មាត្រា២០ ថ្មី (មួយ) មាត្រា២២ ថ្មី មាត្រា២៣ ថ្មី (មួយ) មាត្រា៣១ ថ្មី មាត្រា៣២ មាត្រា៣៧ ថ្មី មាត្រា៤៧ ថ្មី (ពីរ) មាត្រា៥៣ មាត្រា១៣១ និងមាត្រា១៣២ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

១- កថាខណ្ឌ៤ នៃមាត្រា២០ ថ្មី (មួយ) ត្រូវបានកែប្រែដូចខាងក្រោម ៖

៤- ចំពោះប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្តបុគ្គល សហគ្រាសឯកបុគ្គល និងចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រាកំណើនតាមថ្នាក់ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- មាត្រា២៣ ថ្មី (មួយ) ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា២៣ ថ្មី (ពីរ) ដូចខាងក្រោម ៖

**មាត្រា២៣ .- ថ្មី (ពីរ)**

ពន្ធបង់មុនលើការបែងចែកភាគលាភត្រូវបានកំណត់ដូចតទៅ ៖

១- វៀរលែងតែ គម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលស្ថិតក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល ប្រសិនបើសហគ្រាសណាមួយបែងចែកភាគលាភចេញពីប្រាក់ចំណូលមុនបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំទៅឱ្យអ្នកចូលហ៊ុនក្នុងស្រុក ឬអ្នកចូលហ៊ុនបរទេស សហគ្រាសនោះត្រូវបង់ប្រាក់ពន្ធដែលមានចំនួនស្មើនឹងផលគុណនៃទឹកប្រាក់ភាគលាភបំប៉ោងទៅតាមអត្រាពន្ធលើប្រាក់ចំណូល គុណនឹងអត្រាពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដូចមានចែងក្នុងមាត្រា២០ ថ្មី (មួយ) នៃច្បាប់នេះ។

២- ប្រាក់ពន្ធដែលបានបង់តាមកថាខណ្ឌ១ នៃមាត្រានេះត្រូវបានអនុញ្ញាតជាឥណទានពន្ធសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធដែលមានការបែងចែក។ ប្រសិនបើឥណទានពន្ធមានចំនួនលើសពីប្រាក់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យយោងទៅមុខសម្រាប់កាត់កងនឹងពន្ធលើប្រាក់ចំណូលនៃឆ្នាំជាប់ពន្ធបន្តបន្ទាប់។

៣- ភាគលាភដែលបានបង់ពន្ធតាមកថាខណ្ឌ១ នៃមាត្រានេះ នៅពេលបែងចែកបន្តមិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះទៀតទេ។

៤- ពន្ធបង់មុនលើការបែងចែកភាគលាភដូចមានចែងក្នុងមាត្រានេះ មិនអនុវត្តទេចំពោះប្រាក់ចំណូលពីបុព្វលាភធានារ៉ាប់រងឬធានារ៉ាប់រងបន្តលើទ្រព្យសម្បត្តិ ឬហានិភ័យផ្សេងៗនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា២១ ថ្មី នៃច្បាប់នេះ។

៣- វាក្យខណ្ឌ ក វាក្យខណ្ឌ ខ និងវាក្យខណ្ឌ គ នៃកថាខណ្ឌ២ នៃមាត្រា២២ ថ្មី ត្រូវបានកែប្រែដូចខាងក្រោម ៖

ក- មិនត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភតាមមាត្រា២៣ ថ្មី (ពីរ) នៃច្បាប់នេះទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ ថ្មី (មួយ) នៃច្បាប់នេះ

ខ- ត្រូវជាប់ពន្ធបង់មុនលើការបែងចែកភាគលាភតាមមាត្រា២៣ ថ្មី (ពីរ) នៃច្បាប់នេះ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ ថ្មី (មួយ) នៃច្បាប់នេះ និង

គ- ត្រូវជាប់ពន្ធកាត់ទុកតាមមាត្រា២៦ ថ្មី (មួយ) នៃច្បាប់នេះ លើប្រាក់ចំណូលដូចមានចែងក្នុងកថាខណ្ឌ១០ នៃមាត្រា៣៣ ថ្មី នៃច្បាប់នេះ។

៤- កថាខណ្ឌ១ និងកថាខណ្ឌ២ នៃមាត្រា៣៧ ថ្មី ត្រូវកែប្រែដូចខាងក្រោម ៖

១-គណនាបំណុលពន្ធសរុបតាមមាត្រា២០ ថ្មី (មួយ) នៃច្បាប់នេះ។

២-ដកឥណទានពន្ធដែលបានបង់តាមមាត្រា២៣ ថ្មី (ពីរ) និងឥណទានពន្ធបរទេសតាមមាត្រា៣៦ នៃច្បាប់នេះ ប៉ុន្តែមិនឱ្យលើសបំណុលពន្ធក្នុងកថាខណ្ឌ១ នៃមាត្រានេះទេ។

៥- លុបវាក្យខណ្ឌ ង និងលុបពាក្យ "និងលើកលែងតែប្រាក់ចំណូលដែលត្រូវជាប់ពន្ធតាមមាត្រា២២ នៃច្បាប់នេះ" ក្នុងកថាខណ្ឌ១ នៃមាត្រា៩ ថ្មី។

៦- មាត្រា៤៧ ថ្មី (ពីរ) ត្រូវបានធ្វើវិសោធនកម្មជាមាត្រា៤៧ ថ្មី (បី) ដូចខាងក្រោម ៖

**មាត្រា៤៧ .- ថ្មី (បី)**

សម្រាប់និយោជិតនិវាសជន ប្រាក់ពន្ធត្រូវបង់ ត្រូវកំណត់លើប្រាក់បៀវត្សជាប់ពន្ធប្រចាំខែ និងត្រូវកាត់ទុកដោយនិយោជក តាមអត្រាកំណើនតាមថ្នាក់ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៧- ពាក្យ "ពន្ធលើប្រាក់ចំណូលបន្ថែម" ក្នុងមាត្រា៣១ ថ្មី ត្រូវបានជំនួសដោយពាក្យ "ពន្ធបង់មុន"។

៨- ពាក្យ "ថ្ងៃទី១៥" ក្នុងមាត្រា៣១ ថ្មី មាត្រា៣២ និងមាត្រា៥៣ ត្រូវបានជំនួសដោយពាក្យ "ថ្ងៃទី២០"។

៩- ពាក្យ "ការប្រាក់ ២ភាគរយ" ដែលមានចែងក្នុងមាត្រា១៣១ និងមាត្រា១៣២ ត្រូវបានប្តូរទៅជា "ការប្រាក់ ១,៥ភាគរយ"។

**មាត្រា១០ .-**

បទប្បញ្ញត្តិស្តីពីពន្ធតែមប្រិ៍សារពើពន្ធដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើតពន្ធតែមប្រិ៍សារពើពន្ធដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២៣ ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ និងត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

១- ពន្ធតែមប្រើសារពើពន្ធដែលជាគុណប្រយោជន៍ថវិកាថ្នាក់ជាតិ ត្រូវបានផ្ទេរជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត។

២- ពន្ធតែមប្រើសារពើពន្ធកំណត់លើបណ្ណប្រកាសនានា ជាអាទិ៍មានបណ្ណប្រកាសធ្វើឡើងលើកៅស៊ូ ក្រដាសធម្មតា ក្រណាត់ឬវត្ថុផ្សេងៗ ស្លាកអាជីវកម្មដ្ឋាននានា ផ្ទាំងអក្សរឬផ្ទាំងរូបភាពសម្រាប់គោលបំណងពាណិជ្ជកម្ម។

៣-អាជ្ញាធរមានសមត្ថកិច្ចមិនត្រូវចេញលិខិតអនុញ្ញាតទាក់ទងនឹងបណ្ណប្រកាសដែលមិនទាន់បានបង់ពន្ធតែមប្រើសារពើពន្ធឡើយ។

៤- ដែនអនុវត្តនៃពន្ធតែមប្រើសារពើពន្ធ ព្រមទាំងមូលដ្ឋានគិតពន្ធនេះត្រូវកំណត់ដោយអនុក្រឹត្យ។ វិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធតែមប្រើសារពើពន្ធត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ពន្ធតែមប្រើសារពើពន្ធមិនត្រូវអនុវត្តឡើយចំពោះបណ្ណប្រកាសដែលត្រូវបានផ្សព្វផ្សាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញជាអាទិ៍មាន ៖

- ស្លាកយីហោសម្រាប់ការអប់រំសង្គម ការការពារបរិស្ថាន ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ការការពារព្រៃឈើនិងសត្វព្រៃ ការអប់រំច្បាប់ចរាចរណ៍
- ស្លាកយីហោរបស់អង្គការជាតិនិងអង្គការអន្តរជាតិ និង
- ស្លាកយីហោរបស់ស្ថាប័នរដ្ឋ។

៦- ទោសទណ្ឌចំពោះបទល្មើសនានាពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីពន្ធតែមប្រើសារពើពន្ធត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន។

# ជំពូកទី៤

## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ
## ចំណាយថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩

**មាត្រា១១ .-**

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ ទឹកប្រាក់ចំនួន១ ៩២៥ ១៩៨,២លានរៀល ដូចខាងក្រោម ៖

១- ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទចំនួន២០៤ ២០០លានរៀល ដើម្បីទូទាត់ចំណាយបំពេញតម្រូវការផណទានរបស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីប្រមូលទិញស្រូវពីប្រជាកសិករនៅរដូវប្រមូលផលចុងឆ្នាំ២០១៨ និងដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវបង្កើនដើមទុនក្នុងការស្នើសុំអាជ្ញាបណ្ណជាធនាគារពាណិជ្ជ

២- និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការថវិកាបន្ថែមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម ៖

- ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានី ខេត្តចំនួន៣៤២ ៤៥០លានរៀល ដើម្បីបែងចែកទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី ខេត្ត

- ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលក្រុង ស្រុកចំនួន១១ ៣៤៥,១លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន

- ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ សង្កាត់ចំនួន១៣៧ ២០៣,១លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

៣- ទូទាត់ចំណាយវិនិយោគលើការសាងសង់រោងចក្រផលិតអគ្គិសនី ៤០០មេហ្គាវ៉ាត់ចំនួន១ ២៣០ ០០០លានរៀល។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការចំណាយបន្ថែមខាងលើនេះ។

## ជំពូកទី៥
## ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១២ .-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា៣៥ និងមាត្រា៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ សរុបចំនួន៣ ៣២៩ ២៣៦លានរៀល ត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

### ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត

- ចំណូលថវិកាសរុប.................................២ ២៧៨ ៦៩១លានរៀល

  +ចំណូលចរន្តសរុប.................................២ ២៣១ ៦៦៧លានរៀល

  -ចំណូលសារពើពន្ធ..........................២ ០៨៦ ៣០៨លានរៀល

  -ចំណូលមិនមែនសារពើពន្ធ................. ១៤៥ ៣៥៩លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ...................៤៧ ០២៤លានរៀល។

- ចំណាយថវិកាសរុប.................................២ ២៧៨ ៦៩១លានរៀល

  +ចំណាយចរន្ត....................................... ១ ២០៤ ០២៩លានរៀល

  +ចំណាយមូលធន..................................... ៤៦២ ៣៥៦លានរៀល

  +អតិរេករាជធានី ខេត្ត................................ ៦១២ ៣០៦លានរៀល។

ចំណូលរបស់រដ្ឋបាលរាជធានី ខេត្ត តាមមាតិកាថវិកា ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ក២**" និងឥណទានចំណាយបែងចែកទៅតាមរដ្ឋបាលរាជធានី ខេត្តនីមួយៗនិងទៅតាមប្រភេទចំណាយ ត្រូវបានកំណត់ដូចមានចែងក្នុងតារាង "**ខ២**" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

### ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក

- ចំណូលថវិកាសរុប.....................................២៤៧ ២២៨លានរៀល

  +ចំណូលចរន្តសរុប.........................................១២ ១១១លានរៀល

  -ចំណូលមិនមែនសារពើពន្ធ..................... ១២ ១១១លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ................២៣៥ ១១៧លានរៀល។

- ចំណាយថវិកាសរុប.................................... ២៤៧ ២២៨លានរៀល

  +ចំណាយចរន្ត.........................................២៤៧ ២២៨លានរៀល។

### គ.ថវិការបស់រដ្ឋបាលឃុំ សង្កាត់

- ចំណូលថវិកាសរុប..................................... ៨០៣ ៣១៧លានរៀល

  +ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិសរុប............៨០៣ ៣១៧លានរៀល

  -ចំណូលសង្កាត់ចំណុះរាជធានី........... ៤២ ៣៦៨,២៦លានរៀល

  -ចំណូលសង្កាត់ចំណុះក្រុង................ ៦៦ ៣០៤,៤៨លានរៀល

  -ចំណូលឃុំ.............................. ៦៩៤ ៦៤៤,២៦លានរៀល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- ចំណាយថវិកាសរុប.................................... ៨០៣ ៣១៧លានរៀល

+ចំណាយសរុប........................................ ៨០៣ ៣១៧លានរៀល

-ចំណាយសង្កាត់ចំណុះរាជធានី.........៤២ ៣៦៨,២៦លានរៀល

-ចំណាយសង្កាត់ចំណុះក្រុង..............៦៦ ៣០៤,៤៨លានរៀល

-ចំណាយឃុំ.............................. ៦៩៤ ៦៤៤,២៦លានរៀល។

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់នីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាជាជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ។

## ជំពូកទី៦

## បទប្បញ្ញត្តិស្តីពីការធ្វើវិសោធនកម្មមាត្រា៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

### មាត្រា១៣ .-

មាត្រា៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

មាត្រា៤២ .- ថ្មី

ក្នុងករណីការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើឱ្យលេចចេញនូវឱនភាព រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវម្ចាស់ការដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីជានាតុល្យភាពថវិកាឡើងវិញ។ នៅក្នុងឆ្នាំថវិកា ប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិបានកើនលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានអនុម័ត ឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ឬធ្វើនិយ័តកម្មទៅជាគុណាប្រយោជន៍ដល់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនានាដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមកម្រិតចំណូលលើសដែលបានបញ្ជិកា។ នៅដំណាច់ឆ្នាំថវិកា អតិរេកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្ទេរចូលគណនីមូលនិធិរដ្ឋបាលថ្នាក់ក្រោមជាតិនៅរតនាគារជាតិ ដើម្បីយោងបន្តទៅឆ្នាំថវិកាខាងមុខ។ ការប្រើប្រាស់មូលនិធិនេះ ត្រូវគ្រោងឥណទានថវិកាទៅតាមថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។

# ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សុក្រ ៩រោច ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩

ន សីហមុនី

**នរោត្តម សីហមុនី**

នរកម.១២១៩.០២៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិកាថ្នាក់ជាតិ (I+II) | | | | 25.360.028,0 | 30.395.855,0 | 5.035.827,0 | 19,9% |
| I. សរុបចំណូលឆ្លងកាត់ធនាគារជាតិ (ក+ខ) | | | | 20.036.260,0 | 24.342.665,0 | 4.306.405,0 | 21,5% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 19.786.260,0 | 24.092.665,0 | 4.306.405,0 | 21,8% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 19.593.111,0 | 23.899.324,0 | 4.306.213,0 | 22,0% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 19.593.111,0 | 23.899.324,0 | 4.306.213,0 | 22,0% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 16.879.000,0 | 21.091.145,0 | 4.212.145,0 | 25,0% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 14.468.000,0 | 18.321.745,0 | 3.853.745,0 | 26,6% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 4.330.000,0 | 5.080.000,0 | 750.000,0 | 17,3% |
| | | 70011 | ពន្ធលើប្រាក់ចំណូល (រូបវន្តបុគ្គល) | 210.000,0 | 210.000,0 | 0,0 | 0,0% |
| | | 70012 | ពន្ធលើប្រាក់ចំណូល (នីតិបុគ្គល) | 3.250.000,0 | 4.000.000,0 | 750.000,0 | 23,1% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 870.000,0 | 870.000,0 | 0,0 | 0,0% |
| | 7002 | | ពន្ធប្រយោល | 5.901.500,0 | 7.372.800,0 | 1.471.300,0 | 24,9% |
| | | 70022 | អាករលើតម្លៃបន្ថែម | 2.370.500,0 | 3.045.000,0 | 674.500,0 | 28,5% |
| | | 70025 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 851.000,0 | 812.000,0 | -39.000,0 | -4,6% |
| | | 70026 | អាករលើតម្លៃបន្ថែម របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.362.000,0 | 3.166.000,0 | 804.000,0 | 34,0% |
| | | 70027 | អាករលើតម្លៃបន្ថែម របបនាំចូល (ជាបន្ទុករបស់រដ្ឋ) | 318.000,0 | 349.800,0 | 31.800,0 | 10,0% |
| | 7003 | | អាករពិសេស | 4.137.000,0 | 5.733.945,0 | 1.596.945,0 | 38,6% |
| | | 70031 | អាករពិសេសលើទំនិញមួយចំនួន | 900.000,0 | 1.100.000,0 | 200.000,0 | 22,2% |
| | | 70032 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសប្រេងឥន្ធនៈ) | 498.000,0 | 514.500,0 | 16.500,0 | 3,3% |
| | | 70033 | អាករពិសេសលើទំនិញមួយចំនួន របបនាំចូល (សហគ្រាសផ្សេងៗទៀត) | 2.654.000,0 | 4.034.445,0 | 1.380.445,0 | 52,0% |
| | | 70034 | អាករពិសេសលើសេវាមួយចំនួន | 85.000,0 | 85.000,0 | 0,0 | 0,0% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 99.500,0 | 135.000,0 | 35.500,0 | 35,7% |
| | | 70081 | ពន្ធតែមប្រើ | 9.500,0 | 0,0 | -9.500,0 | -100,0% |
| | | 70082 | ប្រាក់ទោសទណ្ឌសារពើពន្ធ | 90.000,0 | 135.000,0 | 45.000,0 | 50,0% |
| 71 | | | ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 2.411.000,0 | 2.769.400,0 | 358.400,0 | 14,9% |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 2.361.000,0 | 2.719.800,0 | 358.800,0 | 15,2% |
| | | 71001 | ពន្ធគយពីការនាំចូល | 1.563.000,0 | 1.970.400,0 | 407.400,0 | 26,1% |
| | | 71002 | កម្រៃពីការងារគយ | 98.000,0 | 72.000,0 | -26.000,0 | -26,5% |
| | | 71003 | ពន្ធគយលើផលិតផលប្រេងឥន្ធនៈ | 340.000,0 | 310.000,0 | -30.000,0 | -8,8% |
| | | 71004 | អាករបន្ថែមលើផលិតផលប្រេងឥន្ធនៈសម្រាប់ថែទាំផ្លូវថ្នល់ | 342.000,0 | 342.000,0 | 0,0 | 0,0% |
| | | 71005 | ផលពីការលក់ទំនិញរឹបអូស និងទំនិញគ្មានការទាមទារ | 500,0 | 500,0 | 0,0 | 0,0% |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 12.000,0 | 12.000,0 | 0,0 | 0,0% |
| | | 71007 | ពន្ធនាំចូល (ជាបន្ទុករបស់រដ្ឋ) | 5.500,0 | 12.900,0 | 7.400,0 | 134,5% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 50.000,0 | 49.600,0 | -400,0 | -0,8% |
| | | 71011 | អាករលើការនាំចេញឈើ | 10.000,0 | 10.000,0 | 0,0 | 0,0% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 33.000,0 | 27.000,0 | -6.000,0 | -18,2% |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 6.500,0 | 12.100,0 | 5.600,0 | 86,2% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500,0 | 500,0 | 0,0 | 0,0% |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 2.714.111,0 | 2.808.179,0 | 94.068,0 | 3,5% |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | 127.416,5 | 220.301,0 | 92.884,5 | 72,9% |
| | 7200 | | ផលសម្បទាន | 106.166,5 | 200.651,0 | 94.484,5 | 89,0% |
| | | 72001 | ផលពីនេសាទ | 2.650,0 | 2.650,0 | 0,0 | 0,0% |
| | | 72002 | ផលពីព្រៃឈើ | 17.412,6 | 17.775,0 | 362,4 | 2,1% |
| | | 72003 | សម្បទានប្រេងកាត | 6.166,0 | 93.101,0 | 86.935,0 | 1409,9% |
| | | 72004 | សម្បទានរ៉ែ | 71.842,9 | 78.384,0 | 6.541,1 | 9,1% |
| | | 72005 | សម្បទានដីសេដ្ឋកិច្ច | 7.000,0 | 7.500,0 | 500,0 | 7,1% |
| | | 72008 | ផលសម្បទានផ្សេងៗ | 1.095,0 | 1.241,0 | 146,0 | 13,3% |
| | 7201 | | ផលទុនពីសហគ្រាសសាធារណៈ | 21.250,0 | 19.650,0 | -1.600,0 | -7,5% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 21.250,0 | 19.650,0 | -1.600,0 | -7,5% |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | 2.295.830,9 | 2.274.997,2 | -20.833,7 | -0,9% |
| | 7300 | | ផលទុនតាមវិស័យ | 955.976,3 | 962.660,5 | 6.684,2 | 0,7% |
| | | 73001 | ផលទុនអាកាសចរស៊ីវិល | 247.016,0 | 261.371,0 | 14.355,0 | 5,8% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 470.464,5 | 482.050,0 | 11.585,5 | 2,5% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 47.132,5 | 44.049,2 | -3.083,3 | -6,5% |
| | | 73005 | ផលទុនពីប្រៃសណីយ៍ និងទូរគមនាគមន៍ | 187.335,0 | 170.445,0 | -16.890,0 | -9,0% |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | 1.164,2 | 939,6 | -224,6 | -19,3% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | 36,8 | 0,0 | -36,8 | -100,0% |
| | | 73008 | ផលទុនផ្សេងៗទៀត | 2.827,3 | 3.805,7 | 978,4 | 34,6% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 103.667,9 | 117.829,4 | 14.161,5 | 13,7% |
| | | 73011 | ការលក់សម្ភារបរិក្ខារ សម្ភារខូចខាត សម្ភារសិក្សា | 124,0 | 120,0 | -4,0 | -3,2% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 103.171,9 | 117.427,4 | 14.255,5 | 13,8% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ | 5,0 | 0,0 | -5,0 | -100,0% |
| | | 73014 | ការលក់ផលិតផលកសិកម្ម | 262,0 | 262,0 | 0,0 | 0,0% |
| | | 73015 | ការលក់មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រចាស់ៗ ឬ ខូច | 23,0 | 20,0 | -3,0 | -13,0% |
| | | 73016 | ការលក់ឧបករណ៍អេឡិចត្រូនិចចាស់ៗ ឬ ខូច | 3,0 | 0,0 | -3,0 | -100,0% |
| | | 73017 | ការលក់ឧបករណ៍អគ្គិសនីចាស់ៗ ឬ ខូច | 2,0 | 0,0 | -2,0 | -100,0% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | 77,0 | 0,0 | -77,0 | -100,0% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 32.889,5 | 70.909,1 | 38.019,6 | 115,6% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 24.635,3 | 24.841,2 | 205,9 | 0,8% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 2.075,5 | 2.094,9 | 19,4 | 0,9% |
| | | 73026 | ចំណូលពីប្រដាប់ក្តី | 4.248,4 | 4.479,4 | 231,0 | 5,4% |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1.930,3 | 39.493,6 | 37.563,3 | 1946,0% |
| | 7304 | | ការផ្តល់សេវាកម្ម | 75.095,0 | 36.789,7 | -38.305,3 | -51,0% |
| | | 73042 | កម្រៃនៃការថែទាំ | 10.870,4 | 12.151,8 | 1.281,4 | 11,8% |
| | | 73043 | សេវាសុរិយោដី | 43.125,0 | 0,0 | -43.125,0 | -100,0% |
| | | 73044 | សេវាសំណង់ | 10.284,0 | 9.000,0 | -1.284,0 | -12,5% |
| | | 73045 | សេវាផ្តល់ព្រឹត្តិបត្រថ្កោលទោស | 2.581,2 | 2.709,6 | 128,4 | 5,0% |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| | | 73047 | សេវាលើពន្ធប្រថាប់ត្រា | 2.000,0 | 2.400,0 | 400,0 | 20,0% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 6.234,4 | 10.528,3 | 4.293,9 | 68,9% |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | 322.156,4 | 258.770,5 | -63.385,9 | -19,7% |
| | | 73061 | ចំណូលពីកាតព្វកិច្ចកាស៊ីណូ | 226.511,0 | 198.089,0 | -28.422,0 | -12,5% |
| | | 73062 | ចំណូលពីកាតព្វកិច្ចឆ្នោត | 2.509,7 | 3.137,1 | 627,4 | 25,0% |
| | | 73065 | ចំណូលពីអាជ្ញាប័ណ្ណនាំចេញ | 50,0 | 35,0 | -15,0 | -30,0% |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | 40.085,7 | 36.509,4 | -3.576,3 | -8,9% |
| | | 73067 | កម្រៃគ្រប់គ្រង និងទិដ្ឋាការនាំចេញ | 53.000,0 | 21.000,0 | -32.000,0 | -60,4% |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 32.692,7 | 35.217,0 | 2.524,3 | 7,7% |
| | | 73071 | ការជួលដីទំនេរ | 16.628,4 | 18.109,3 | 1.480,9 | 8,9% |
| | | 73072 | ការជួលដីមានអគារ | 12.823,9 | 16.776,3 | 3.952,4 | 30,8% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 3.000,0 | 71,4 | -2.928,6 | -97,6% |
| | | 73074 | ការជួលសម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូន និងគ្រឿងចក្រ | 240,4 | 260,0 | 19,6 | 8,2% |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 773.353,1 | 792.821,0 | 19.467,9 | 2,5% |
| | | 73081 | ចំណូលពីការផ្តល់លិខិតឆ្លងដែន | 181.924,0 | 165.340,8 | -16.583,2 | -9,1% |
| | | 73082 | ចំណូលពីការផ្តល់ទិដ្ឋាការ | 446.757,0 | 580.791,2 | 134.034,2 | 30,0% |
| | | 73083 | ចំណូលពីការលក់លេខចុះបញ្ជីយានយន្ត | 4.300,0 | 6.000,0 | 1.700,0 | 39,5% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 6.493,8 | 650,0 | -5.843,8 | -90,0% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | 6.075,4 | 400,0 | -5.675,4 | -93,4% |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 5.272,8 | 4.324,0 | -948,8 | -18,0% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | 122.530,1 | 35.315,0 | -87.215,1 | -71,2% |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | **31.274,3** | **33.945,8** | **2.671,5** | **8,5%** |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | 22.212,3 | 21.945,8 | -266,5 | -1,2% |
| | | 74011 | ការពិន័យជាប្រាក់លើបទល្មើសចរាចរណ៍ផ្លូវគោក | 10.000,0 | 10.255,6 | 255,6 | 2,6% |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | 12.212,3 | 11.690,2 | -522,1 | -4,3% |
| | 7403 | | ចំណូលពីការរឹបអូស | 9.000,0 | 12.000,0 | 3.000,0 | 33,3% |
| | | 74032 | ចំណូលពីការរឹបអូសទ្រព្យសម្បត្តិ | 9.000,0 | 12.000,0 | 3.000,0 | 33,3% |
| | 7408 | | ផលពីការពិន័យផ្សេងៗ | 62,0 | 0,0 | -62,0 | -100,0% |
| | | 74081 | ផលពីការពិន័យផ្សេងៗ | 62,0 | 0,0 | -62,0 | -100,0% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | **132.201,3** | **132.000,0** | **-201,3** | **-0,2%** |
| | 7504 | | ឧបត្ថម្ភធនពីក្រៅប្រទេស | 0,0 | 130.000,0 | 130.000,0 | |
| | | 75042 | ឧបត្ថម្ភធនពីក្រៅប្រទេសពហុភាគី | 0,0 | 130.000,0 | 130.000,0 | |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | 132.201,3 | 2.000,0 | -130.201,3 | -98,5% |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | 2.201,3 | 2.000,0 | -201,3 | -9,1% |
| | | 75088 | ចំណូលពីប្រភពផ្សេងៗទៀត | 130.000,0 | 0,0 | -130.000,0 | -100,0% |
| 76 | | | **ផលហិរញ្ញវត្ថុ** | **127.379,0** | **146.926,0** | **19.547,0** | **15,3%** |
| | 7601 | | ការប្រាក់នៃការឱ្យខ្ចីនិងការប្រាក់នៃប្រាក់បញ្ញើ | 127.379,0 | 146.926,0 | 19.547,0 | 15,3% |
| | | 76011 | ការប្រាក់លើការឱ្យខ្ចី | 127.379,0 | 146.926,0 | 19.547,0 | 15,3% |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | **9,0** | **9,0** | **0,0** | **0,0%** |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក១"

## ចំណូលថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| | 7704 | | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 3,0 | 3,0 | 0,0 | 0,0% |
| | | 77041 | ចំណូលពីការលក់អគារជម្រះបញ្ជីសារពើភណ្ឌ | 3,0 | 3,0 | 0,0 | 0,0% |
| | 7705 | | ចំណូលពីការលក់ថេយន្ត ឧបករណ៍ និងសម្ភារបរិក្ខារ ជាអចលនវត្ថុ | 6,0 | 6,0 | 0,0 | 0,0% |
| | | 77052 | ចំណូលពីការលក់ថេយន្ត | 3,0 | 3,0 | 0,0 | 0,0% |
| | | 77054 | ចំណូលពីការលក់ឧបករណ៍ការិយាល័យនិងគ្រឿងសង្ហារឹម | 3,0 | 3,0 | 0,0 | 0,0% |
| **ខ.សរុបចំណូលមូលធន (ក្រុមទី១ + ក្រុមទី២)** | | | | 443.149,0 | 443.341,0 | 192,0 | 0,0% |
| **ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)** | | | | 443.149,0 | 443.341,0 | 192,0 | 0,0% |
| **ប្រភេទទី១ : ចំណូលពីប្រភពផ្ទាល់** | | | | 193.149,0 | 193.341,0 | 192,0 | 0,1% |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | 193.149,0 | 193.341,0 | 192,0 | 0,1% |
| | 2701 | | ការឱ្យខ្ចី (ការសងវិញនូវមូលធន) | 193.149,0 | 193.341,0 | 192,0 | 0,1% |
| | | 27011 | ការឱ្យខ្ចី ទៅសហគ្រាសសាធារណៈ | 193.149,0 | 193.341,0 | 192,0 | 0,1% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | 250.000,0 | 250.000,0 | 0,0 | 0,0% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 125.000,0 | 162.000,0 | 37.000,0 | 29,6% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 125.000,0 | 162.000,0 | 37.000,0 | 29,6% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 125.000,0 | 162.000,0 | 37.000,0 | 29,6% |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | 125.000,0 | 88.000,0 | -37.000,0 | -29,6% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 125.000,0 | 88.000,0 | -37.000,0 | -29,6% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 125.000,0 | 88.000,0 | -37.000,0 | -29,6% |
| **II. សរុបចំណូលអនុវត្តក្រៅធនាគារជាតិ** | | | | 5.323.768,0 | 6.053.190,0 | 729.422,0 | 13,7% |
| **ប្រភេទទី២ : ចំណូលពីប្រភពខាងក្រៅ** | | | | 5.323.768,0 | 6.053.190,0 | 729.422,0 | 13,7% |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 1.064.753,0 | 958.277,0 | -106.476,0 | -10,0% |
| | 7514 | | ឧបត្ថម្ភធនពីក្រៅប្រទេស សម្រាប់ចំណាយវិនិយោគ | 1.064.753,0 | 958.277,0 | -106.476,0 | -10,0% |
| | | 75141 | ឧបត្ថម្ភធនពីក្រៅប្រទេស-ទ្វេភាគី សម្រាប់ចំណាយវិនិយោគ | 319.426,0 | 287.483,0 | -31.943,0 | -10,0% |
| | | 75142 | ឧបត្ថម្ភធនពីក្រៅប្រទេស-ពហុភាគី សម្រាប់ចំណាយវិនិយោគ | 745.327,0 | 670.794,0 | -74.533,0 | -10,0% |
| 50 | | | **ការខ្ចីប្រាក់ និងបំណុលប្រហាក់ប្រហែល** | 4.259.015,0 | 5.094.913,0 | 835.898,0 | 19,6% |
| | 5002 | | ការខ្ចីក្រៅប្រទេស | 4.259.015,0 | 5.094.913,0 | 835.898,0 | 19,6% |
| | | 50021 | ការខ្ចីក្រៅប្រទេស-ពហុភាគី | 1.703.606,0 | 2.037.965,0 | 334.359,0 | 19,6% |
| | | 50022 | ការខ្ចីក្រៅប្រទេស-ទ្វេភាគី | 2.555.409,0 | 3.056.948,0 | 501.539,0 | 19,6% |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិការាជធានី ខេត្ត (I+II) | | | | 1.476.946,0 | 2.278.691,0 | 801.745,0 | 54,3% |
| I. សរុបចំណូលឆ្លងកាត់រតនាគារជាតិ (ក+ខ) | | | | 1.476.946,0 | 2.278.691,0 | 801.745,0 | 54,3% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 1.476.946,0 | 2.278.691,0 | 801.745,0 | 54,3% |
| ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២) | | | | 1.476.946,0 | 2.278.691,0 | 801.745,0 | 54,3% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 1.476.946,0 | 2.278.691,0 | 801.745,0 | 54,3% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 1.351.616,7 | 2.086.308,0 | 734.691,3 | 54,4% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1.351.616,7 | 2.086.308,0 | 734.691,3 | 54,4% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 324.237,0 | 396.163,0 | 71.926,0 | 22,2% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 251.440,0 | 303.146,0 | 51.706,0 | 20,6% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (នីតិបុគ្គល) | 72.797,0 | 93.017,0 | 20.220,0 | 27,8% |
| | 7003 | | អាករពិសេស | 178.996,2 | 223.869,0 | 44.872,8 | 25,1% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 178.996,2 | 223.869,0 | 44.872,8 | 25,1% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 21.766,7 | 24.812,0 | 3.045,3 | 14,0% |
| | | 70045 | អាករលើការស្នាក់នៅ | 21.766,7 | 24.812,0 | 3.045,3 | 14,0% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 283.675,0 | 335.976,0 | 52.301,0 | 18,4% |
| | | 70053 | ពន្ធប៉ាតង់ | 58.175,0 | 65.001,0 | 6.826,0 | 11,7% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 225.500,0 | 270.975,0 | 45.475,0 | 20,2% |
| | 7006 | | ពន្ធប្រថាប់ត្រា | 431.824,3 | 940.737,0 | 508.912,7 | 117,9% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 412.248,2 | 915.475,0 | 503.226,8 | 122,1% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 7.371,3 | 10.818,0 | 3.446,7 | 46,8% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 921,5 | 1.018,0 | 96,5 | 10,5% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវា | 6.088,6 | 7.537,0 | 1.448,4 | 23,8% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 5.194,7 | 5.889,0 | 694,3 | 13,4% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 111 117,5 | 147.751,0 | 36.633,5 | 33,0% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 96.784,0 | 128.447,0 | 31.663,0 | 32,7% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 8.325,0 | 10.069,0 | 1.744,0 | 20,9% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 6.008,5 | 9.235,0 | 3.226,5 | 53,7% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | | 17.000,0 | 17.000,0 | |
| | | 70081 | ពន្ធតែមប្រ៍ | | 17.000,0 | 17.000,0 | |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 125.329,3 | 192.383,0 | 67.053,7 | 53,5% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 7.967,1 | 9.501,7 | 1.534,6 | 19,3% |
| | 7200 | | ផលសម្បទាន | 7.967,1 | 9.501,7 | 1.534,6 | 19,3% |
| | | 72004 | សម្បទានរ៉ែ | 5.393,4 | 7.371,6 | 1.978,2 | 36,7% |
| | | 72006 | ចំណតយានជំនិះ | 1.827,9 | 1.480,7 | -347,2 | -19,0% |
| | | 72007 | ចំណតជលយាន | 372,3 | 624,4 | 252,1 | 67,7% |
| | | 72008 | ផលសម្បទានផ្សេងៗ | 373,5 | 25,0 | -348,5 | -93,3% |
| 73 | | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 33.554,2 | 133.213,0 | 99.658,8 | 297,0% |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| | 7300 | | ផលទុនតាមវិស័យ | 10.512,5 | 13.102,7 | 2.590,2 | 24,6% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | | 1.184,5 | 1.184,5 | |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | | 55,2 | 55,2 | |
| | | 73006 | ផលទុនពីវិទ្យុ និងទូរទស្សន៍ | | 198,8 | 198,8 | |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនី និងទឹក | | 39,0 | 39,0 | |
| | | 73008 | ផលទុនផ្សេងៗទៀត | 10.512,5 | 11.625,2 | 1.112,7 | 10,6% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | | 2.618,5 | 2.618,5 | |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | | 2.583,5 | 2.583,5 | |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ ផ្សេងៗទៀត | | 35,0 | 35,0 | |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល (1) | 5.166,1 | 12.077,7 | 6.911,6 | 133,8% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | | 3.838,7 | 3.838,7 | |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | | 405,7 | 405,7 | |
| | | 73028 | ចំណូលពីការអនុញ្ញាតរដ្ឋបាល ទម្រង់ការរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 5.166,1 | 7.833,3 | 2.667,2 | 51,6% |
| | 7304 | | ការផ្តល់សេវាកម្ម | 7.788,0 | 77.524,6 | 69.736 6 | 895.4% |
| | | 73042 | កម្រៃនៃការថែទាំ | | 752,3 | 752,3 | |
| | | 73043 | សេវាសុរិយោដី | 5.722,0 | 68.052,0 | 62.330,0 | 1089,3% |
| | | 73044 | សេវាសំណង់ | 773,9 | 6.858,0 | 6.084,1 | 786,2% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 1 292,1 | 1.862,3 | 570,2 | 44,1% |
| | 7305 | | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងទៀត | 8.046,8 | 7.545,4 | -501,4 | -6,2% |
| | | 73051 | ចំណូលពីសត្តឃាតដ្ឋាន | 921,0 | 874,6 | -46,4 | -5,0% |
| | | 73052 | ការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 1.732,6 | 1.694,7 | -37,9 | -2,2% |
| | | 73053 | ចំណូលពីកំពង់ចម្លង | 1.052,4 | 1.063,1 | 10,7 | 1,0% |
| | | 73054 | ចំណូលពីឃ្លាំត្រី និងកន្លែងបែងចែកផលិតផល | 119,3 | 121,3 | 2,0 | 1,7% |
| | | 73055 | ចំណូលពីភាសីផ្សារ | 3.458,5 | 3.028,7 | -429,8 | -12,4% |
| | | 73058 | ផលពីទ្រព្យសម្បត្តិអចល័តផ្សេងៗ | 763,0 | 763,0 | | |
| | 7306 | | កម្រៃប្រតិបត្តិការផ្សេងៗទៀត | | 1.346,7 | 1.346,7 | |
| | | 73066 | ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក | | 1.346,7 | 1.346,7 | |
| | 7307 | | ការជួលទ្រព្យសម្បត្តិរដ្ឋ | 59,4 | 61,4 | 2,0 | 3,4% |
| | | 73071 | ការជួលដីទំនេរ | 2,4 | 4,4 | 2,0 | 83,3% |
| | | 73073 | ការជួលអគារ ឬ សំណង់ផ្សេងៗ | 57,0 | 57,0 | | |
| | 7308 | | ផលពីការគ្រប់គ្រងរដ្ឋបាល (2) | 1.981,4 | 18.936,0 | 16.954,6 | 855,7% |
| | | 73084 | ចំណូលពីការចុះបញ្ជីយានយន្ត និងជលយាន | 281,8 | 6.090,4 | 5.808,6 | 2061,2% |
| | | 73085 | ចំណូលពីការផ្តល់ប័ណ្ណបើកបរគ្រប់ប្រភេទ | | 7.969,6 | 7.969,6 | |
| | | 73086 | ផលពីការត្រួតពិនិត្យអនាម័យសត្វ | 1.699,6 | 3.301,4 | 1.601,8 | 94,2% |
| | | 73087 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាន | | 1.574,6 | 1.574,6 | |
| 74 | | | **ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម** | | **1.733,3** | **1.733,3** | |
| | 7401 | | ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | | 1.703,3 | 1.703,3 | |
| | | 74012 | ការពិន័យ និងការដាក់ទណ្ឌកម្មពិន័យជាប្រាក់ | | 1.703,3 | 1.703,3 | |

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ក២"

## ចំណូលថវិការាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ទឹកប្រាក់ | ភាគរយ |
| | 7408 | | ផលពីការពិន័យផ្សេងៗ | | 30,0 | 30,0 | |
| | | 74081 | ផលពីការពិន័យផ្សេងៗ | | 30,0 | 30,0 | |
| 75 | | | **ការឧបត្ថម្ភ និង អំណោយ** | 83.808,0 | 47.935,0 | -35.873,0 | -42,8% |
| | 7501 | | ឧបត្ថម្ភធនពីថ្នាក់ជាតិ | 83.808,0 | 47.024,0 | -36.784,0 | -43,9% |
| | | 75011 | ឧបត្ថម្ភធនពីក្រសួង-ស្ថាប័ន | 83.808,0 | 47.024,0 | -36.784,0 | -43,9% |
| | 7508 | | ចំណូលពីប្រភពផ្សេងៗ | | 911,0 | 911,0 | |
| | | 75081 | ផលពីការរួមចំណែកការពារបរិស្ថាន | | 911,0 | 911,0 | |

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២០

## តារាង "ខ១"

## ចំណាយថវិកាថ្នាក់ជាតិ

ឯកតា:លានរៀល

| ក្រសួង ស្ថាប័ន | សរុបរួមចំណាយ | ចំណាយចរន្ត: សរុបចំណាយចរន្ត | ចំណាយចរន្ត: ប្រភេទទី១ មធ្យោបាយនិងសេវា | ចំណាយចរន្ត: ប្រភេទទី២ បន្ទុកហិរញ្ញវត្ថុ | ចំណាយចរន្ត: ប្រភេទទី៣ អន្តរាគមន៍សាធារណៈ | ចំណាយចរន្ត: ប្រភេទទី៤ ចំណាយផ្សេងៗ | ចំណាយចរន្ត: ប្រភេទទី៦ ចំណាយមិនបានគ្រោងទុក | ចំណាយមូលធន: សរុបចំណាយមូលធន | ចំណាយមូលធន: ប្រភេទទី១ ការទូទាត់ការខ្ចី | ចំណាយមូលធន: ប្រភេទទី២ អចលកម្ម |
|---|---|---|---|---|---|---|---|---|---|---|
| សរុបរួមចំណាយ | 31.095.855,0 | 18.036.884,0 | 12.069.797,2 | 542.077,0 | 4.056.166,2 | 529.959,6 | 838.884,0 | 13.058.971,0 | 1.105.922,0 | 11.953.049,0 |
| រដ្ឋបាលកណ្តាល | 20.583.391,8 | 13.577.610,8 | 7.835.709,2 | 542.077,0 | 3.832.259,6 | 528.681,0 | 838.884,0 | 7.005.781,0 | 1.105.922,0 | 5.899.859,0 |
| -ក្នុងនោះគ្រឹះស្ថានសាធារណៈរដ្ឋបាល | 262.574,1 | 262.574,1 | | | 262.574,1 | | | 0 | | 0 |
